# គណៈកម្មការទន្លេមេគង្គ

**ការិយាល័យលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គនៅភ្នំពេញ**
ផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម
ប្រអប់សំបុត្រលេខ ៦២៣ ទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៨៥៥-២៣ ៤២៥ ៣៥៣.
ទូរសារលេខ ៨៥៥-២៣ ៤២៥ ៣៦៣

**ការិយាល័យលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គនៅវៀងច័ន្ទ**
ការិយាល័យប្រធានលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គ
អគារលេខ ១៨៤ ផ្លូវហ្វា ងុម សាធារណៈរដ្ឋប្រជាធិបតេយ្យ
ប្រជាមានិតឡាវ ប្រអប់សំបុត្រលេខ ៦១០១ ទីក្រុងវៀងច័ន្ទ ០១០០០
ទូរស័ព្ទលេខ ៨៥៦-២១ ២៦៣ ២៦៣
ទូរសារលេខ ៨៥៦-២១ ២៦៣ ២៦៤


## សំណួរដែលលើកឡើងជាញឹកញាប់

## ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ (SEA) របស់គណៈកម្មការទន្លេមេគង្គ លើសំណើគម្រោងថាមពលវារីអគ្គិសនីនៅលើដងទន្លេមេនៃទន្លេមេគង្គ

សំណួរនានាដែលបានលើកឡើងជាញឹកញាប់ (FAQs) ដូចខាងក្រោមនេះ បានសង្ខេបនូវរបកគំហើញសំខាន់ៗអំពី ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ (SEA) ដែលធ្វើឡើងដោយគណៈកម្មការទន្លេមេគង្គ (MRC) លើសំណើគម្រោងថាមពលវារីអគ្គិសនីនៅលើដងទន្លេមេនៃទន្លេមេគង្គ-របាយការណ៍ចុងក្រោយ។ សំណួរនានាដែលបានលើកឡើងជាញឹកញាប់ទាំងនេះ មានគោលបំណងសង្ខេបនូវការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនេះទៅជាចំណុចខ្លីៗ និងបកស្រាយសំណួរខ្លះៗដែល ពុំមានបកស្រាយនៅក្នុងរបាយការណ៍នេះ។ សំណួរចំបងៗដែលបានឆ្លើយនៅក្នុងបញ្ជីសំណួរចម្លើយនេះ រួមមាន: *តើសេចក្តីសន្និដ្ឋានចំបងៗអ្វីខ្លះ ដែលមានបង្ហាញនៅក្នុងរបាយការណ៍ចុងក្រោយនេះ? តើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនេះ ទាក់ទងនឹងនីតិវិធីសម្រាប់ដំណើរការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA) ដែរឬទេ? តើ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនេះ ទាក់ទងបែបណាទៅនឹងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ (BDP)? និងតើគណៈកម្មការទន្លេមេគង្គមានទស្សនៈបែបណាអំពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ?*

### សាវតានៃការវាយតម្លៃជាយុទ្ធសាស្ត្រ (SEA)

*តើ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រជាអ្វី?*

- ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ បង្ហាញអំពីកិច្ចការយុទ្ធសាស្ត្រធំទូលាយដែលទាក់ទងនឹងគោលនយោបាយ ឬកម្មវិធីនានា ដែលមិនស្ថិតនៅក្នុងគម្រោងតែមួយ: ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ អនុវត្តតាមជំហានប្រហាក់ប្រហែលគ្នានឹង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIAs) សម្រាប់គម្រោងជាក់លាក់ដែរ ប៉ុន្តែមានវិសាលភាព

ធំទូលាយជាងយ៉ាងច្រើន លើពេលវេលា ទីកន្លែង និងប្រធានបទ។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ គឺជាឧបករណ៍មួយដើម្បីពិនិត្យមើលកង្វល់ជាយុទ្ធសាស្ត្រធំទូលាយ ដែលត្រូវតែដោះស្រាយ និងធ្វើការសម្រេចឱ្យបានរួចរាល់ មុននឹងសេចក្តីសម្រេចអំពីគម្រោងជាក់លាក់។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដែលចាត់ចែងឡើងដោយ គណៈកម្មការទន្លេមេគង្គ ផ្តល់នូវការយល់ដឹងអំពីការពាក់ព័ន្ធនៃសំណើអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅលើទន្លេមេនៃទន្លេមេគង្គ និងអនុសាសន៍នានាអំពីថាតើគម្រោងបែបនេះគួរតែស្ថិតក្រោមការពិចារណាដោយប្រទេសជាសមាជិកដែរឬទេ និងថាតើគួរពិចារណាបែបណា ដើម្បីឱ្យផ្តល់ផលប្រសើរបំផុត។

- ដំណើរការការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ គឺជាអភិក្រមទូលំទូលាយមួយសម្រាប់ជួយប្រទេសជាសមាជិក និងអ្នកពាក់ព័ន្ធនានា ក្នុងការប៉ាន់ ប្រមាណហានិភ័យ និងឱកាសសម្រាប់ការកសាងសំណើគម្រោងថាមពលវារីអគ្គិសនីនៅលើទន្លេមេនៃទន្លេមេគង្គ: ទោះបីរបាយការណ៍នៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការវិភាគនៅក្នុងរបាយការណ៍នេះ មិនមែនរៀបចំឡើងដោយគណៈកម្មការទន្លេមេគង្គឡើយ ប៉ុន្តែបានធ្វើឡើងដោយ ក្រុមទីប្រឹក្សាផ្នែកការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រក៏ដោយ ដំណើរការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវបានសម្របសម្រួល និងទទួលមូលនិធិ តាមរយៈគំនិតផ្តួចផ្តើមរបស់គណៈកម្មការទន្លេមេគង្គ ស្តីពីនិរន្តរភាពថាមពលវារីអគ្គិសនី (ISH)។ គំនិតផ្តួចផ្តើមស្តីពីវារីអគ្គិសនីប្រកបដោយនិរន្តរភាព (ISH) ជាគំនិតផ្តួចផ្តើមអន្តរវិស័យដែលធ្វើការជាមួយគ្រប់កម្មវិធីទាំងអស់របស់គណៈកម្មការទន្លេមេគង្គ។ ដំណើរការនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ចែកជាបួនដំណាក់កាលចំបងៗ: (i) ការវិសាលភាព (ii) ការប៉ាន់ប្រមាណអំពីលក្ខខណ្ឌគោល (iii) ការប៉ាន់ប្រមាណអំពីឱកាស និងហានិភ័យ និង (iv) ការប៉ាន់ប្រមាណអំពីការបញ្ចៀស ការកែលម្អ និងការបន្ធូរបន្ថយ។ ដំណាក់កាលនីមួយៗ រួមបញ្ចូលការរៀបចំ និងការចែកផ្សាយនូវរបាយការណ៍នានា ដែល ជាមូលដ្ឋានសម្រាប់ការពិគ្រោះយោបល់ និងផ្តល់យោបល់តប។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ គឺជាដំណើរការសហការមួយដែលពាក់ព័ន្ធជាមួយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ទីភ្នាក់ងារនៃរដ្ឋាភិបាលនៅក្នុងប្រទេសសមាជិកទាំងបួន ក៏ដូចជាសង្គមស៊ីវិល វិស័យឯកជន អ្នកពាក់ព័ន្ធដទៃទៀត និងវិទ្យាស្ថានស្រាវជ្រាវមកពីប្រទេសចិនផងដែរ។ ដំណើរការនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ បានទទួលការអនុម័តដោយគណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ ដែលជាផ្នែកមួយនៃកម្មវិធីការងារទាំងមូលនៃគំនិតផ្តួចផ្តើមស្តីពីនិរន្តរភាពថាមពលវារីអគ្គិសនី។

- ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ គឺជាការឆ្លើយតបទៅនឹងកំណើនចំណាប់អារម្មណ៍លើការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅតាមទន្លេមេនៃទន្លេមេគង្គ: ចំណាប់អារម្មណ៍លើការអភិវឌ្ឍនៅលើទន្លេមេនៃទន្លេមេគង្គ កើនឡើងតាមលំនាំនៃកំណើនចំណាប់អារម្មណ៍លើថាមពលវារីអគ្គិសនី ដើម្បីអភិវឌ្ឍន៍ធនធានថាមពលនៅក្នុងស្រុក ពោលគឺចំណាប់អារម្មណ៍របស់ប្រទេសឡាវ និងកម្ពុជា ក្នុងការបង្កើតផលចំណូលពីការលក់ថាមពលទៅក្រៅប្រទេស ដើម្បីបំពេញតាមតម្រូវការថាមពល ដែលកាន់តែកើនឡើងនៅក្នុងប្រទេសថៃ និងវៀតណាម ក៏ដូចជាកំណើនការយកចិត្តទុកដាក់

ជាសកលលើការកាត់បន្ថយនូវការបំភាយកាបូនពីការផលិតអគ្គិសនីផងដែរ។ ទន្ទឹមនឹងនេះ ការបញ្ចប់គម្រោងថាមពលវារីអគ្គិសនីខ្នាតធំនៅក្នុងប្រទេសចិន ដែលនឹងនាំឱ្យមានកំណើនធារទឹកនារដូវប្រាំងនៅក្នុងតំបន់ខ្សែទឹកខាងក្រោម កំណើនសក្តានុពលសម្រាប់ការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅលើទន្លេមេនៃទន្លេមេគង្គក្នុងអាងទន្លេមេគង្គក្រោម។ សំណើគម្រោងជាច្រើនត្រូវបានធ្វើអត្តសញ្ញាណអស់រយៈពេល១៥ឆ្នាំ មកហើយ ប៉ុន្តែចំណាប់អារម្មណ៍ក្នុងចំណោមក្រុមហ៊ុនអភិវឌ្ឍន៍នៃវិស័យឯកជន នាពេលថ្មីៗនេះ ដែលភាគច្រើនមានប្រភពនៅក្នុងតំបន់អាស៊ីដែល បាននាំឱ្យផែនការអភិវឌ្ឍន៍ថាមពលវារីអគ្គិសនីឈានដល់ដំណាក់កាលនៃការសិក្សាលទ្ធភាព នៅក្រោមប្រព័ន្ធនិយ័តកម្ម ដែលបានបង្កើតឡើងដោយរដ្ឋាភិបាល។ អាស្រ័យហេតុនេះ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ គឺជាការឆ្លើយតបទៅនឹងទំហំនៃចំណាប់អារម្មណ៍របស់វិនិយោគិន និងក្រុមហ៊ុនអភិវឌ្ឍន៍លើគម្រោងថាមពលវារីអគ្គិសនីចំនួន ១២ ដែលបានលើកស្នើសម្រាប់កសាងនៅតាមទន្លេមេនៃទន្លេមេគង្គក្រោម។ របាយការណ៍នៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ នេះមានគោលដៅផ្តល់នូវវិធានសម្រាប់ការរៀបចំ និងគោលគំនិតសម្រាប់ ដំណើរការពិគ្រោះយោបល់ជាផ្លូវការដែលគ្រោងចាត់ចែងឡើងដោយ គណៈកម្មការទន្លេមេគង្គ នៅក្រោមដំណើរការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង ដើម្បីបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍អាងទន្លេ (Basin Development Plan)របស់គណៈកម្មការទន្លេ មេគង្គ និងនៅទីបំផុត គឺផ្តល់ជាមូលដ្ឋានសម្រាប់ដំណើរការធ្វើសេចក្តីសម្រេចរបស់ជាតិ ដែលទាក់ទងនឹងសំណើនានានៅលើទន្លេមេនៃទន្លេមេគង្គ។

- ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រត្រូវបានរៀបចំឡើងដោយផ្អែកលើបទពិសោធន៍ដំណើរការកម្មវិធីរបស់គណៈកម្មការទន្លេមេគង្គ: ក្នុងនាមជាដំណើរការប្រកបដោយការចូលរួម និងដែលគ្មានបោះបង់ចោលភាគីណាមួយ របាយការណ៍នៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ពឹងផ្អែកជាខ្លាំងលើការងារជាច្រើនឆ្នាំនៃកម្មវិធីរបស់គណៈកម្មការទន្លេមេគង្គ ជាពិសេស ការវាយតម្លៃលើសេណារីយ៉ូនៅក្នុងផែនការអភិវឌ្ឍន៍អាងទន្លេ (BDP ជំហានទី២) ក្រុមកសាងម៉ូដែលនៅក្នុងកម្មវិធីគ្រប់គ្រងព័ត៌មាន និងចំណេះដឹង (IKMP) ទិន្នន័យ និងការសិក្សានានានៃកម្មវិធីបរិស្ថាន ជលផល និងនាវាចរ។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ បានបង្ហាញពីការពិគ្រោះយោបល់ទូលំទូលាយជាមួយស្ថាប័ននានារបស់រដ្ឋាភិបាល សង្គមស៊ីវិល ក្រុមហ៊ុនអភិវឌ្ឍន៍នៅក្នុងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នៅថ្នាក់ជាតិក្នុងប្រទេសទាំងបួននៃអាងទន្លេមេគង្គក្រោម។ នៅថ្នាក់តំបន់ ប្រទេសចិនបានចូលរួមនៅក្នុងដំណើរការនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ តាមរយៈគណៈកម្មការសិក្សាប្រព័ន្ធអេកូឡូស៊ីសម្រាប់ទន្លេអន្តរជាតិ (Ecosystem Study Commission for International Rivers) ដោយផ្លាស់ប្តូរព័ត៌មានតាមរយៈក្រុមកសាងម៉ូដែល ដោយសម្រួលឱ្យមានទស្សនៈកិច្ចនៅតាមទំនប់នានាក្នុងប្រទេសចិន និងការចូលរួមនៅក្នុងសិក្ខាសាលាអំពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ នៅថ្នាក់តំបន់។

- ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ប្រឹងប្រែងកំណត់ឱកាសដែលអាចមាន វិភាគទាន និងហានិភ័យ ដោយធ្វើការវាយតម្លៃអំពីយុទ្ធសាស្ត្រជំនួសសម្រាប់អភិវឌ្ឍន៍ថាមពលវារីអគ្គិសនីនៅលើទន្លេមេនៃទន្លេមេគង្គ: ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ផ្តោតការយកចិត្តទុកដាក់ដោយឡែកទៅលើរបាយនៃការបង់ខាត និងផលចំណេញនៅក្នុងតំបន់ ដែលទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច សមធម៌សង្គម និងកិច្ចការពារបរិស្ថាន។ ក្នុងន័យនេះ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ គាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍អាងទន្លេ (BDP) ដោយបំពេញបន្ថែមលើការប៉ាន់ប្រមាណអំពីផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ដោយគណៈកម្មការទន្លេមេគង្គ នៅក្នុងការបង្កើតសេណារីយ៉ូអភិវឌ្ឍន៍ ជាមួយការវិភាគកាន់តែស៊ីជម្រៅលើឱកាស និងហានិភ័យ ដែលទាក់ទងនឹងថាមពល និងការអភិវឌ្ឍអន្តរវិស័យនៃសំណើគម្រោង លើទន្លេមេនៃទន្លេមេគង្គក្រោម។

- ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ផ្តល់នូវការសន្និដ្ឋាន និងអនុសាសន៍ ដែលនាំមកបញ្ចូលគ្នានូវការវាយតម្លៃជាយុទ្ធសាស្ត្រសម្រាប់គម្រោងទាំង ១២ លើទន្លេមេនៃទន្លេមេគង្គក្រោម នៅក្នុងបរិបទនៃការអភិវឌ្ឍទន្លេមេគង្គដោយចីរភាព និងការអនុវត្តកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥: ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ផ្តល់បន្ថែមនូវព័ត៌មានគោល និងក្របខ័ណ្ឌនៃការវាយតម្លៃសម្រាប់រដ្ឋាភិបាល ធ្វើការពិនិត្យនៅក្នុងដំណាក់កាលបន្ទាប់មក នៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIAs) សម្រាប់គម្រោងជាក់លាក់ និងដែលត្រូវរៀបចំឡើងដោយ ក្រុមហ៊ុនអភិវឌ្ឍន៍។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ នឹងជួយគណៈកម្មការទន្លេមេគង្គ ធ្វើការសម្រេចអំពីអាទិភាពខ្លះៗ របស់ខ្លួនលើការសិក្សាស្រាវជ្រាវ និងអង្កេត ដែលកម្មវិធីរបស់គណៈកម្មការទន្លេមេគង្គ ត្រូវអនុវត្តដើម្បីកាត់បន្ថយហានិភ័យ និងភាពមិនប្រាកដប្រជាអំពីការអភិវឌ្ឍទំនប់នៅលើទន្លេមេនៃទន្លេមេគង្គ។

## សមិទ្ធផលនៃ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

*តើសារណែនាំសំខាន់ៗអ្វីខ្លះ ដែលជាសមិទ្ធផលនៅក្នុងរបាយការណ៍ចុងក្រោយអំពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ?*

- *ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្របង្ហាញពីឱកាស និងហានិភ័យ ដែលពាក់ព័ន្ធជាមួយការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅលើទន្លេមេនៃទន្លេមេគង្គ:* សំណើគម្រោងទាំង ១២ នៅលើទន្លេមេនៃទន្លេមេគង្គក្រោម ផ្តល់នូវហានិភ័យយ៉ាងច្រើននៅក្នុងការអភិវឌ្ឍ ក៏ដូចជាឱកាសយ៉ាងច្រើនសម្រាប់ការអភិវឌ្ឍនៅក្នុងបណ្តាប្រទេសក្នុង អាងទន្លេមេគង្គក្រោមផងដែរ។ ហានិភ័យខ្លះៗដែលបានធ្វើអត្តសញ្ញាណឃើញ រួមមានការខាតបង់ធនធានជលផល ដែលទាក់ទងជាមួយឥទ្ធិពលមកលើរបរចិញ្ចឹមជីវិត និងអាហារូបត្ថម្ភ ការប្រែប្រួលលំហូរកំទេចកំណក និងតុល្យភាពរវាងកំទេចកំណក-សារធាតុចិញ្ចឹម និងភាពចម្រុះនៃអេកូឡូស៊ី។ ឱកាសនានា រួមមានផលប្រយោជន៍យ៉ាងច្រើនពីថាមពល ដែលនាំឱ្យមានកំណើនសេដ្ឋកិច្ចជាតិ ផលប្រយោជន៍ខាងសេដ្ឋកិច្ច-សង្គម ដែលកើតចេញពីកំណើនផលចំណូលដែលបានពីការធ្វើសម្បទាន

វិស័យនេះទៅឱ្យឯកជន លទ្ធភាពច្រើនជាងមុនក្នុងការធ្វើនាវាចរ ដោយសារតែកំណើនកម្រិតកំពស់ទឹក សក្តានុពលនៃការស្រោចស្រពនៅក្នុងមូលដ្ឋាន និងការទូទាត់រវាងការបំភាយ ឧស្ម័នពីស្ថានីយ៍ផលិតថាមពលកំដៅ ដូច្នេះជាការបញ្ចៀសបាននូវការបំភាយជាតិកាបូន។

សេចក្តីសង្ខេបនៅក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្តអំពីឱកាស និងហានិភ័យខាងសេដ្ឋកិច្ចសម្រាប់ប្រទេសនានានៅក្នុងអាងទន្លេមេគង្គក្រោម ដោយសារតែគម្រោងទាំង ១២ ដែលលើកស្នើនៅលើទន្លេមេនៃទន្លេមេគង្គនៅតាមអាងទន្លេមេគង្គក្រោម

<table>
<tr><td colspan="2">កម្ពុជា<br>- ផលវិបាកអវិជ្ជមានធ្ងន់ធ្ងរមកលើវិស័យជលផល និងអ្នកនេសាទ សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ<br>- ផលចំណេញយ៉ាងច្រើនពីការអភិវឌ្ឍវិស័យថាមពល ដែលមានថ្លៃថោកជាងមុន និងដែលអាចធានាបានសម្រាប់ការបង្កើនភាពសម្បូរបែបនៅក្នុងវិស័យឧស្សាហកម្ម និងសេដ្ឋកិច្ច សំរាបរយៈពេលវែង<br>- ការបាត់បង់ក្នុងវិស័យជលផលទំនងជាមានទំហំធំជាងផលប្រយោជន៍ពីការផលិតថាមពល យ៉ាងហោចណាស់នៅក្នុងរយៈពេលខ្លីដល់រយៈពេលមធ្យម</td></tr>
<tr><td>ឱកាស</td><td>ហានិភ័យ</td></tr>
<tr><td>- ផលប្រយោជន៍យ៉ាងច្រើនពីការផ្គត់ផ្គង់ថាមពលដែលមិនសូវថ្លៃ និងអាចធានាបាននៅក្នុងប្រទេស (ជំនួសការនាំចូលប្រេងម៉ាហ្សូតដែលមានថ្លៃខ្ពស់)<br>- កំណើនភាពប្រកួតប្រជែងក្នុងវិស័យសហគ្រាសផលិតកម្ម<br>- កំណើនផលចំណូលសម្រាប់រដ្ឋាភិបាលដែលបានពីការលក់ចេញថាមពលទៅក្រៅប្រទេស និងចំណូលពីពន្ធ<br>- កំណើនផ្ទៃដីស្រោចស្រព និងផលិតភាពកសិកម្មនៅក្នុងតំបន់ខ្លះ<br>- ភាពបត់បែនជាយុទ្ធសាស្រ្តសម្រាប់រយៈពេលវែងលើការផ្គត់ផ្គង់ថាមពលក្រោយពេលសម្បទានត្រូវបញ្ចប់។</td><td>- ការខាតបង់ធនធានជលផល និងឥទ្ធិពលយ៉ាងខ្លាំងមកលើសន្តិសុខស្បៀង<br>- ការរំខានលើរបរចិញ្ចឹមជីវិតរបស់អ្នកនេសាទច្រើនជាង 1,6 លាននាក់<br>- ការខាតបង់ផលិតផលសរុបក្នុងស្រុក (GDP) ដោយសារការខាតបង់សេដ្ឋកិច្ចក្នុងវិស័យជលផល និងកសិកម្ម<br>- សេវាកម្មបន្ទាប់បន្សំ និងការកែច្នៃ ត្រូវរងការខូចខាត<br>- ថយចុះកំទេចកំណក និងសារធាតុចិញ្ចឹមដែលពាក់ព័ន្ធនឹងប្រព័ន្ធបឹងទន្លេសាប និងឥទ្ធិពលអវិជ្ជមានដែលពាក់ព័ន្ធមកលើផលិតកម្មបឋម ព្រៃលិចទឹក និងមច្ឆជាតិក្នុងមូលដ្ឋាន/ត្រីធ្វើចរាចរ<br>- ការបាត់បង់សួនបន្លែតាមច្រាំងទន្លេ ទំនងជាមានទំហំក្រាស់ក្រែលសម្រាប់សហគមន៍តាមដងទន្លេក្នុងកន្លែងខ្លះៗ<br>- បាត់បង់ដីជាតិនិងផលិតភាពកសិកម្មក្នុងតំបន់ទំនាបលិចទឹក<br>- ការបាត់បង់ប្រភពទាក់ទាញ និងផលចំណូលពីទេសចរណ៍<br>- កង្វះបណ្តាញថាមពលនៅថ្នាក់ជាតិអាចរារាំងការចែកចាយថាមពលឱ្យមានសមធម៌</td></tr>
</table>

<table>
<tr><td></td><td>- ការបាត់បង់ជីវៈចម្រុះ</td></tr>
<tr><td colspan="2">ប្រទេសឡាវ<br>- ផលចំណេញខាងសេដ្ឋកិច្ចជារួម ទំនងជាមានទំហំធំធេង និងទំនងជាមានការបែងចែកផលមិនបានស្មើគ្នា<br>- ឥទ្ធិពលអវិជ្ជមានមកលើសហគមន៍ងាយរងគ្រោះ ទំនងជាមានទំហំធំធេង<br>- ការចំណាយកាន់តែច្រើនឡើងរបស់រដ្ឋាភិបាលឡាវ នូវប្រាក់ចំណេញ អាចជួយកាត់បន្ថយឥទ្ធិពលអវិជ្ជមាន។</td></tr>
<tr><td>ឱកាស</td><td>ហានិភ័យ</td></tr>
<tr><td>- ផលប្រយោជន៍យ៉ាងច្រើនពីការជម្រុញកម្លាំងសេដ្ឋកិច្ចតាមរយៈ ការវិនិយោគផ្ទាល់ពីបរទេស (FDI) លើថាមពលវារីអគ្គិសនីលើដងទន្លេមេគង្គក្នុងអាងទន្លេមេគង្គក្រោម។<br>- អាចមើលឃើញថា ផលចំណេញក្នុងរយៈពេលសម្បទាន ខុសគ្នាអាស្រ័យតាមទម្រង់នៃកិច្ចព្រមព្រៀងហិរញ្ញប្បទាន និងសមត្ថភាពគ្រប់គ្រាន់នៅក្នុងការត្រួតពិនិត្យ<br>- ទំនងជាឃើញថា មានផលចំណេញច្រើន នៅក្រោយរយៈពេលសម្បទាន ២៥ ឆ្នាំ និងពេលផ្ទេរគម្រោងទៅរដ្ឋាភិបាលឡាវវិញ<br>- ផលចំណេញពីកំណើនផ្ទៃដីស្រោចស្រព និងផលិតភាពកសិកម្មក្នុងកន្លែងខ្លះៗ<br>- កំណែលម្អនាវាចរសម្រាប់នាវាខ្នាតតូច/មធ្យមទៅតំបន់ខ្សែទឹកខាងលើនៃទីក្រុងវៀងច័ន្ទ<br>- ភាពបត់បែនជាយុទ្ធសាស្ត្រសម្រាប់រយៈពេលវែងលើការផ្គត់ផ្គង់ថាមពលក្រោយពេលសម្បទានត្រូវបញ្ចប់។</td><td>- អាចមានកំណើនអតុល្យភាពម៉ាក្រូសេដ្ឋកិច្ចដោយសារតែកំណើនខ្លាំងលើវិស័យថាមពលវារីអគ្គិសនី<br>- ការខាតបង់ជលផល ទំនងជាមានឥទ្ធិពលលើសន្តិសុខស្បៀងនិងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋដែលងាយរងគ្រោះ<br>- បាត់បង់ដីណាំតាមច្រាំងទន្លេ ដែលមានទំហំក្រាស់ក្រៃល ជាពិសេសនៅក្នុងប្រទេសឡាវ<br>- បាត់បង់ប្រភពទាក់ទាញដ៏មានតម្លៃសម្រាប់ទេសចរ<br>- បាត់បង់ជីវៈចម្រុះ</td></tr>
<tr><td colspan="2">ប្រទេសថៃ<br>- ផលចំណេញខាងសេដ្ឋកិច្ចជារួម បើទោះជាមិនមានទំហំធំធេងសម្រាប់សេដ្ឋកិច្ចជាតិក៏ដោយ<br>- ហានិភ័យខាងសេដ្ឋកិច្ចចំពោះការចិញ្ចឹមជីវិតសម្រាប់សហគមន៍តាមដងទន្លេនេះ</td></tr>
<tr><td>ឱកាស</td><td>ហានិភ័យ</td></tr>
<tr><td>- នឹងទទួលបានចំណែកយ៉ាងច្រើនជាផលចំណូលសេដ្ឋកិច្ច ពីការទិញចូលថាមពលមកពីក្រៅប្រទេស<br>- កំណែលម្អនាវាចរសម្រាប់នាវាខ្នាតតូចនិងមធ្យមនៅតំបន់ខ្សែទឹកខាងលើនៃ LMB</td><td>- បាត់បង់ជលផល<br>- បាត់បង់ដីកសិកម្ម<br>- អាចបាត់បង់ប្រភពទាក់ទាញអេកូទេសចរណ៍</td></tr>
<tr><td colspan="2">វៀតណាម</td></tr>
</table>

| | |
|---|---|
| - ទំនងជាខាតបង់សេដ្ឋកិច្ចជារួម<br>- ការខាតបង់ភាគច្រើនក្នុងចំណោមសហគមន៍ក្រីក្រនៅក្នុងដែនដីសណ្តទន្លេមេគង្គ។ | |
| ឱកាស<br>- នឹងទទួលបានភាគចំណែកច្រើនក្រាស់ក្រែលពីផលប្រយោជន៍ខាងសេដ្ឋកិច្ចដោយសារតែកំណើននៃការផ្គត់ផ្គង់ថាមពល (ថាមពលទិញមកពីក្រៅប្រទេស) | ហានិភ័យ<br>- ខាតបង់យ៉ាងច្រើននូវផលនេសាទនិងវារីវប្បកម្មទឹកសាបនិងសមុទ្រ - ទំនងជាមានឥទ្ធិពលលើការចិញ្ចឹមជីវិតរបស់អ្នកនេសាទនៅដែនដីសណ្តរ ជាពិសេសក្រុមអ្នកក្រីក្រ<br>- បាត់បង់កំទេចកំណកនិងសារធាតុចិញ្ចឹមដែលពាក់ព័ន្ធ ឥទ្ធិពលអវិជ្ជមានក្រាស់ក្រែលមកលើសេដ្ឋកិច្ច វត្តមានកំទេចកំណកនៅដែនដីសណ្តរ ជលផល(ទន្លេមេគង្គនិងសមុទ្រ) និងកសិកម្ម។ |

- របាយការណ៍នៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ពិចារណាជម្រើសយុទ្ធសាស្ត្រចំនួនបួនសម្រាប់ការអភិវឌ្ឍថាមពលលើដងទន្លេមេគង្គ: របាយការណ៍នៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ បានអធិប្បាយ និងពិគ្រោះយោបល់អំពីជម្រើសយុទ្ធសាស្ត្រចំនួនបួន :

  (i) គ្មានទំនប់នៅលើទន្លេមេនៃទន្លេមេគង្គ

  (ii) ពន្យារពេលនៃការសម្រេចអំពីការសាងសង់ទំនប់ទាំងអស់នៅលើទន្លេមេនៃទន្លេមេគង្គក្នុងរយៈពេលណាមួយកំណត់

  (iii) ការអភិវឌ្ឍថាមពលនៅលើទន្លេមេនៃទន្លេមេគង្គបន្តិចម្តងៗ និង

  (iv) ការអភិវឌ្ឍគម្រោងទំនប់នៅលើទន្លេមេនៃទន្លេមេគង្គ ដោយផ្អែកលើតម្រូវការនៃទីផ្សារ។

*តើមានសេចក្តីសន្និដ្ឋានចំបងៗអ្វីខ្លះនៅក្នុងរបាយការណ៍នេះ?*

- ក្រុមទីប្រឹក្សាសរសេររបាយការណ៍អំពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រលើកស្នើឱ្យមានការពន្យាពេល ១០ឆ្នាំ ទាក់ទងនឹងការអភិវឌ្ឍថាមពលវារីអគ្គិសនីលើទន្លេមេនៃទន្លេមេគង្គ: ក្រុមទីប្រឹក្សាដែលធ្វើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ បានណែនាំថា ដោយសារតែភាពមិនប្រាកដប្រជា ដែលទាក់ទងនឹងទំហំ និងភាពមិនអាចជួសជុលបាននៃហានិភ័យនៅក្នុងប្រព័ន្ធទន្លេដ៏សាំញ៉ាំបែបនេះ ការសម្រេចនានាអំពីទំនប់នៅលើទន្លេមេនៃទន្លេមេគង្គ គួរតែពន្យារពេលរហូតដល់ ១០ ឆ្នាំ ដោយត្រូវមានការពិនិត្យឡើងវិញរៀងរាល់ឆ្នាំ ដើម្បីធានាឱ្យមានលក្ខខណ្ឌចាំបាច់សម្រាប់បង្កើនការស្វែងយល់អំពីប្រព័ន្ធធម្មជាតិ ក៏ដូចជាដំណើរការគ្រប់គ្រង និងតម្រូវការឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាពនូវរបបនិយ័តកម្មផងដែរ។
- ឥទ្ធិពលឆ្លងដែន គឺជាសារគន្លឹះ: ត្រូវពិនិត្យមើលឥទ្ធិពលនៃរចនាសម្ព័ន្ធទំនប់នៅលើទន្លេមេនៃទន្លេមេគង្គក្នុងអាងទន្លេមេគង្គក្រោម ដោយប្រៀបធៀបជាមួយឥទ្ធិពលសរុប និងឥទ្ធិពលឆ្លងដែនបណ្តាលពីកំណើនចំនួនគម្រោងថាមពលវារីអគ្គិសនីនៅលើដៃទន្លេនេះនៅក្នុងអាងទន្លេមេគង្គក្រោម និងទំនប់ស្ទាក់ទឹកនៅក្នុងអាងទន្លេឡាំងឆាននៃប្រទេសចិន។ ការពិនិត្យឡើងវិញនូវឥទ្ធិពល ដែលអាចកើតមានបង្កដោយគម្រោងនីមួយៗដាច់ដោយឡែកពីគ្នា មិនផ្តល់នូវទិដ្ឋភាព

ទាំងមូលឡើយ។ ឥទ្ធិពលជាក់លាក់ (វិជ្ជមាន និងអវិជ្ជមាន) នៃសំណើគម្រោងទំនប់លើទន្លេមេនៃទន្លេមេគង្គ គឺជាការបន្ថែមឥទ្ធិពលមកលើប្រព័ន្ធថាមពលវារីអគ្គិសនីខ្នាតធំ ដែលបានគ្រោងសាងសង់នៅលើដៃទន្លេមេគង្គរហូតដល់ឆ្នាំ ២០១៥ ប្រព័ន្ធស្ទាក់ទឹកចំនួន ៨ នៅក្នុងអាងទន្លេឡាំងឆាងនៃប្រទេសចិន ក៏ដូចជា ឥទ្ធិពលរួមនៃសម្ពាធបណ្តាលពីកត្តានានាផ្សេងទៀតក្រៅពីទំនប់មកលើប្រព័ន្ធធនធានធម្មជាតិនៃទន្លេមេគង្គផងដែរ។

- ត្រូវធានាឱ្យមានសមធម៌នៃផលប្រយោជន៍ពីការអភិវឌ្ឍ នៅថ្នាក់ជាតិ និងមូលដ្ឋាន: បញ្ហាស្នូលមួយនៅក្នុងរបាយការណ៍នៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ គឺរបាយនៃការបង់ខាត និងផលចំណេញ ទាំងនៅថ្នាក់តំបន់ និងមូលដ្ឋាន។ ផលប្រយោជន៍សម្រាប់ជាតិដែលបានពីការផលិតអគ្គិសនី ត្រូវតែចែករំលែកជាមួយសហគមន៍ដែលរងការខូចខាតនិង ដែលងាយរងគ្រោះនៅតាមដងទន្លេ។ ផលប្រយោជន៍ដែលអាចទទួលបាននៅថ្នាក់តំបន់ ឬថ្នាក់ជាតិ ក៏ត្រូវតែចែករំលែកជាមួយក្រុមងាយរងគ្រោះផងដែរ ដែលអាចរងឥទ្ធិពលអវិជ្ជមានធំធេងបំផុត ក្រោមរូបភាពជាការបាត់បង់ឱកាសក្នុងការចិញ្ចឹមជីវិតពីធនធានតាមដងទន្លេ អាហារូបត្ថម្ភ និងការបាត់បង់វប្បធម៌។ ប្រការសំខាន់គឺត្រូវទទួលស្គាល់ថា ឥទ្ធិពលទាំងនេះមានលក្ខណៈជាការបន្ថែមពីលើគ្នា និងឆ្លងដែន។

**ទស្សនៈវិស័យរបស់ គណៈកម្មការទន្លេមេគង្គ ទាក់ទងនឹងរបាយការណ៍ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ**

*ក្នុងនាមជាស្ថាប័នផ្តល់យោបល់បច្ចេកទេស តើលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គមានការគាំទ្រកម្រិតណាចំពោះអនុសាសន៍ក្នុងរបាយការណ៍អំពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រចុងក្រោយនេះ?*

- ទាក់ទងនឹងការសិក្សាណាមួយក៏ដោយដែលបានចាត់ចែងឡើង របាយការណ៍អំពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ មិនមែនជាឯកសារដែលទទួលការអនុម័តជាផ្លូវការពីគណៈកម្មការទន្លេមេគង្គឡើយ: របាយការណ៍ចុងក្រោយនេះ នៅត្រូវការឱ្យមានការពិភាក្សាដោយអង្គភាពនានារបស់គណៈកម្មការទន្លេមេគង្គ អាស្រ័យហេតុនេះមិនសុទ្ធតែតំណាងឱ្យទស្សនៈ ការសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មការទន្លេមេគង្គឡើយ។ ឯកសារនេះត្រូវបានរៀបរៀងឡើងសម្រាប់គណៈកម្មការទន្លេមេគង្គ ដោយក្រុមទីប្រឹក្សាផ្នែកការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដើម្បីជួយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ លើការប្រមូលព័ត៌មាន។
- របាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រចុងក្រោយនេះ និងឯកសារពាក់ព័ន្ធនានា នឹងត្រូវផលិត និងចែកផ្សាយឱ្យបានទូលំទូលាយដល់ភាគីទាំងអស់ដែលពាក់ព័ន្ធនឹងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនេះ: សេចក្តីសង្ខេបរបាយការណ៍ចុងក្រោយនេះត្រូវបានប្រែសម្រួលជាភាសាចំនួនបួននៃប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ។ របាយការណ៍នេះ និងអនុសាសន៍នានា នឹងត្រូវដាក់សម្រាប់ការពិភាក្សាជាមួយអង្គភាពនានារបស់គណៈកម្មការទន្លេមេគង្គ ដែលរួមទាំងគណៈកម្មាធិការជាតិទន្លេមេគង្គ និងគណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ។ មុខនាទីចំបងមួយចំពោះមុខ គឺផ្តល់ជាមូលដ្ឋានផ្លូវការមួយសម្រាប់ដំណើរការពិគ្រោះយោបល់ជាមុនរបស់គណៈកម្មការទន្លេមេគង្គ (សូមអានសំណួរដែលលើកឡើងជាញឹកញាប់ដូចខាងក្រោម) ស្តីពីសំណើគម្រោងសាងសង់ទំនប់នីមួយៗ

នៅលើដងទន្លេមេគង្គ ដូចជាសំណើកសាងទំនប់សាយ៉ាប៊ូរីដែរ។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ផ្តល់នូវក្របខ័ណ្ឌចាំបាច់មួយអំពីការវាយតម្លៃហេតុប៉ះពាល់សរុប ដែលនឹងអាចពិនិត្យឡើងវិញសម្រាប់គម្រោងនីមួយៗ នៅពេលក្រោយមក។

- គណៈកម្មការទន្លេមេគង្គ គាំទ្រដល់ប្រទេសជាសមាជិកក្នុងការរៀបចំខ្លួនដើម្បីធ្វើការសម្រេចនានាអំពីសំណើគម្រោងថាមពលវារីអគ្គិសនីលើទន្លេមេនៃទន្លេមេគង្គក្នុងគោលដៅឈានដល់កិច្ចព្រមព្រៀងរួមមួយៈ គោលបំណងមួយ ក្នុងចំណោមគោលបំណងនានានៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនេះ គឺធ្វើអត្តសញ្ញាណកម្មនៃចំណេះដឹងអំពីបញ្ហា គន្លឹះនានាដែលមានឥទ្ធិពលមកលើអាងទន្លេមេគង្គក្រោមទាំងមូល និងដើម្បីធ្វើការវិនិច្ឆ័យប្រកបដោយការយល់ដឹងក្នុងការឈានទៅលើកអនុសាសន៍របស់ខ្លួន។ ក្រោយមានដំណើរការពិគ្រោះយោបល់រួមគ្នារួចហើយ ប្រសិនបើប្រទេសជាសមាជិកសម្រេចធ្វើការអភិវឌ្ឍនៅលើដងទន្លេមេគង្គ គណៈកម្មការទន្លេមេគង្គ នឹងគាំទ្រដល់ប្រទេសជាសមាជិកក្នុងការផ្តល់នូវការណែនាំចាំបាច់លើការកសាងផែនការ និងការកសាងគម្រោងប្លង់ ដែលទាក់ទងនឹងនិរន្តរភាពនៃគម្រោង និងកាត់បន្ថយឥទ្ធិពលឆ្លងដែន ក៏ដូចជាលក្ខខណ្ឌនៃការតាមដានផងដែរ។
- ការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅលើដងទន្លេមេគង្គ មានលក្ខណៈសាំញ៉ាំ ចម្រូងចម្រាស់ និងមិនអាចប្រែក្រឡាស់បានឡើយៈ គេចាំបាច់ត្រូវមានការឯកភាពមតិលើចក្ខុវិស័យសម្រាប់រយៈពេលវែងអំពីតុល្យភាពរវាងការអភិវឌ្ឍ និងកិច្ចការពារធនធានទឹក។ ការធ្វើសមាហរណកម្មនូវការសម្រេចទាំងនេះ រួមជាមួយយុទ្ធសាស្ត្រវិស័យថាមពល គោលនយោបាយជាតិ និងកិច្ចព្រមព្រៀងទ្វេភាគី និងប្រចាំតំបន់ នៅក្នុងវិស័យថាមពល ក៏ដូចជាវិស័យផ្សេងទៀតដែលរងឥទ្ធិពល (ជលផល កសិកម្ម និងនាវាចរ) ក៏ត្រូវតែគិតបញ្ចូលផងដែរអំពីការពាក់ព័ន្ធជាមួយយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ទើបអាចសម្រេចបានចំណុចដៅនៃការអភិវឌ្ឍរបស់ជាតិ។

*តើគណៈកម្មការទន្លេមេគង្គ នឹងមានចំណាត់ការអ្វីខ្លះបន្ទាប់ពីរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនេះ?*

- គណៈកម្មការទន្លេមេគង្គ នឹងធ្វើឱ្យសាធារណជនមានលទ្ធភាពអានរបាយការណ៍ចុងក្រោយស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនៅតាមគេហទំព័រ៖ បន្ថែមលើនេះ គណៈកម្មការទន្លេមេគង្គ បានប្រែសម្រួលសេចក្តីសង្ខេបនៃរបាយការណ៍ចុងក្រោយទៅជាភាសានៃប្រទេសទាំងបួនដែលមាននៅក្នុងគេហទំព័ររបស់គណៈកម្មការទន្លេមេគង្គផងដែរ គឺ http://www.mrcmekong.org/ish/SEA.htm
- គណៈកម្មការទន្លេមេគង្គ នឹងលើកស្នើឱ្យធ្វើការពិគ្រោះយោបល់ជាមួយកម្មវិធីនានារបស់គណៈកម្មការទន្លេមេគង្គ និងអាចជាមួយប្រទេសជាសមាជិកផងដែរ លើរបាយការណ៍ចុងក្រោយនេះ និងរបកគំហើញ និងអនុសាសន៍របស់ខ្លួនសម្រាប់ជំហានខាងមុខ។
- អនុសាសន៍នៅក្នុងចុងក្រោយស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រជួយគណៈកម្មការទន្លេមេគង្គ នៅក្នុងការកសាងផែនការកម្មវិធីរបស់ខ្លួនទៅអនាគតៈ អនុសាសន៍នានាសម្រាប់ចំណាត់ការនៅក្នុងរបាយការណ៍ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដូចជាការស្រាវជ្រាវ ការប្រមូលទិន្នន័យ ការតាមដាន និងដំណើរការពិគ្រោះយោបល់ និងការពង្រឹងប្រព័ន្ធគ្រប់គ្រង និងនិយ័តកម្ម អាចជួយដល់គណៈកម្មការទន្លេមេគង្គ នៅក្នុងការកសាងផែនការការងារ

តាមកម្មវិធីរបស់ខ្លួន សម្រាប់បណ្តាឆ្នាំខាងមុខ ក្រោមកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានារបស់គណៈកម្មការទន្លេមេគង្គ។

**ទស្សនៈវិស័យរបស់អ្នកពាក់ព័ន្ធនានាអំពីរបាយការណ៍នៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត**

*តើអ្វីខ្លះជាទស្សនៈវិស័យរបស់អ្នកពាក់ព័ន្ធនានាអំពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត*

- ដំណើរការនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្តបានទទួលការពិគ្រោះយោបល់យ៉ាងសកម្ម: របាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត បានពាក់ព័ន្ធជាមួយស្ថាប័នច្រើនជាង ៦០ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលចំនួន ៤០ និងអង្គការអភិវឌ្ឍន៍អន្តរជាតិប្រមាណ ២០ នៅក្នុងការជួបប្រជុំ និងសិក្ខាសាលានានា។ ដំណើរការនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត មានការចូលរួមពីប្រទេសចិនតាមរយៈគណៈកម្មការសិក្សាប្រព័ន្ធអេកូឡូស៊ីសម្រាប់ទន្លេអន្តរជាតិ (ESCIR)។ ទោះជាយ៉ាងណាក៏ដោយ របាយការណ៍ចុងក្រោយនេះ នៅតែជាផលិតផលរបស់ក្រុមទីប្រឹក្សា និងនៅពុំទាន់ជាប្រធានបទនៃការពិគ្រោះយោបល់របស់ប្រទេសទាំងនេះឡើយ។
- ទស្សនៈរបស់អ្នកពាក់ព័ន្ធនានាអំពីការអភិវឌ្ឍនៅក្នុងអាងទន្លេមេគង្គក្រោម មានភាពខុសគ្នា ដូចដែលបង្ហាញនៅទូទាំងដំណើរការនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត: ទស្សនៈរបស់អ្នកពាក់ព័ន្ធបានបង្កើតជាមូលដ្ឋានសម្រាប់ជម្រើសយុទ្ធសាស្រ្តចំនួនបួនដែលបាន បង្ហាញជូននៅក្នុងដំណាក់កាលចុងក្រោយនៃដំណើការការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្តក្នុងការបង្ហាញនូវទស្សនៈស្តីពីការបញ្ចៀស ការពន្យាពេល ឬ ការឈានទៅធ្វើការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅតាមទន្លេមេនៃទន្លេមេគង្គ។ អនុសាសន៍អំពីការពន្យារពេល បានធ្វើឡើងដោយក្រុមទីប្រឹក្សា ដោយផ្អែកលើការវាយតម្លៃរបស់ខ្លួន។
- ការឯកភាពមតិរបស់អ្នកពាក់ព័ន្ធនានាលើប្រធានបទនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត រួមមានការបង្កើននូវការប្រាស្រ័យឆ្លើយឆ្លងជាមួយសហគមន៍រងគ្រោះ និងការបែងចែកផលដោយសមធម៌: អ្នកពាក់ព័ន្ធនានាបានឯកភាពថា រដ្ឋាភិបាលនៅថ្នាក់ជាតិត្រូវធ្វើការដោះស្រាយផលប៉ះពាល់ឆ្លងដែនឱ្យបានទូលំទូលាយ ដែលរួមទាំងជាមួយអ្នកដែលនឹងត្រូវរងគ្រោះ ដោយសារគម្រោងនានាដែលកំពុងស្ថិតក្នុងការអនុវត្តទៅហើយ។ យុទ្ធសាស្រ្តប្រាស្រ័យឆ្លើយឆ្លងនិងការផ្លាស់ប្តូរព័ត៌មានក្នុងចំណោមសហគមន៍រស់នៅតាមដងទន្លេ ក៏ត្រូវកែកែលម្អផងដែរ ដើម្បីជួយឱ្យសហគមន៍យល់ដឹងអំពីវិសាលភាពទាំងមូលនៃផលប៉ះពាល់មកលើពួកគេ។ អ្នកពាក់ព័ន្ធនានា ក៏បានឯកភាពគ្នាផងដែរឱ្យមានចំណាត់ការសំខាន់ៗដើម្បីធានាឱ្យមានការបែងចែកផល និងរបាយនៃការខូចខាតដោយសមធម៌ ដែលកើតចេញពីការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅនៅតាមទន្លេមេនៃទន្លេមេគង្គ។ គេត្រូវបង្កើតយន្តការនានា ដើម្បីផ្តល់ផលប្រយោជន៍ដល់សហគមន៍រងគ្រោះតាមរយៈការបែងចែកផលដែលកើតមាននៅថ្នាក់ជាតិ ដើម្បីដោះស្រាយកង្វល់លើការបែងចែកផល។
- ប្រទេសចិនបានចូលរួមក្នុងនាមជាអ្នកពាក់ព័ន្ធសំខាន់មួយតាមរយៈគណៈកម្មការសិក្សាប្រព័ន្ធអេកូឡូស៊ីសម្រាប់ទន្លេអន្តរជាតិ **(ESCIR)** : ក្នុងនាមជាដៃគូសន្ទនាមួយរបស់គណៈកម្មការទន្លេមេគង្គ ប្រទេសចិន រួមជាមួយប្រទេសភូមា

បានចូលរួមនៅក្នុងសិក្ខាសាលាថ្នាក់ជាតិ ការផ្លាស់ប្តូរទិន្នន័យនិងព័ត៌មាន និងការបង្ហាញជូនដល់អ្នកពាក់ព័ន្ធដទៃទៀតអំពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។ គណៈកម្មការសិក្សាប្រព័ន្ធអេកូឡូស៊ីសម្រាប់ទន្លេអន្តរជាតិ បានចាត់ចែងឱ្យមានការធ្វើទស្សនៈកិច្ចរបស់គណៈកម្មការទន្លេមេគង្គ នៅប្រទេសចិនផងដែរ។

**របាយការណ៍នៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍អាងទន្លេ**

*តើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រទាក់ទងបែបណាជាមួយ ផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ?*

- តើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រទាក់ទងនឹងពេលវេលា និងផ្តល់នូវគំនិតជាយុទ្ធសាស្ត្រទៅក្នុងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គដែលមានសព្វថ្ងៃដែរឬទេ? ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ក៏ជាផ្នែកមួយនៃក្របខ័ណ្ឌវាយតម្លៃខាងផ្លូវច្បាប់ ដែលជាលក្ខខណ្ឌចាំបាច់របស់ប្រទេសនៅក្នុងអាងទន្លេមេគង្គក្រោមកាន់តែច្រើនឡើងផងដែរ។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ លើសំណើគម្រោងថាមពលវារីអគ្គិសនីនៅលើទន្លេមេនៃទន្លេមេគង្គ ផ្តោតលើផ្នែកមួយនៃក្របខ័ណ្ឌធំទូលាយនៃផែនការអភិវឌ្ឍន៍អាងទន្លេ និងបង្ហាញដោយជាក់លាក់នូវហានិភ័យ និងឱកាសនៃគម្រោងមួយចំនួនដែលមានការជំទាស់ខ្លាំងបំផុត។ ផែនការអភិវឌ្ឍន៍អាងទន្លេ គឺជាផ្នែករួមមួយនៃកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥ និងជាដំណើរការកសាងផែនការរំកិលរួមមួយដើម្បីជួយប្រទេស ជាសមាជិករបស់ គណៈកម្មការទន្លេមេគង្គ ក្នុងការអភិវឌ្ឍ និងគ្រប់គ្រងទឹក និងធនធានក្នុងទន្លេមេគង្គប្រកបដោយចីរភាព និងសមធម៌។ ផែនការអភិវឌ្ឍន៍អាងទន្លេ ធ្វើការនៅទូទាំងវិស័យដែលទាក់ទងនឹងទឹក (ការស្រោចស្រព នាវាចរ ជលផល ការគ្រប់គ្រងទឹក កិច្ចការពារបរិស្ថាន។ល) ការវិភាគភាពបំពេញគ្នាដែលអាចកើតមាន និងទំនាស់រវាងវិស័យទាំងនោះ ដើម្បីផ្តល់នូវទស្សនៈវិស័យនៅទូទាំងអាងទន្លេ ទាំងមូល អំពីថាតើផែនការអភិវឌ្ឍន៍ធនធានទឹករបស់ជាតិ ដែលរួមទាំងការអភិវឌ្ឍថាមពលវារីអគ្គិសនី មានលក្ខណៈល្អប្រសើរកម្រិតណា ក្នុងការជួយសម្រេចឱ្យបាននូវតុល្យភាពដែលអាចទទួលយកបាន រវាងសមិទ្ធផលខាងសេដ្ឋកិច្ច បរិស្ថាន និងសង្គមនៅក្នុងអាងទន្លេមេគង្គក្រោម។

- ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍អាងទន្លេមានវិសាលភាពខុសគ្នា: វិសាលភាពនៃផែនការអភិវឌ្ឍន៍អាងទន្លេ មានមិនត្រឹមតែជាការគិតគូរអំពីទំនប់នៅលើដងទន្លេមេគង្គនោះទេ ប៉ុន្តែថែមទាំងពិនិត្យមើលនូវទិដ្ឋភាពធំទូលាយនៃសេណារីយ៉ូអភិវឌ្ឍន៍ទៅអនាគត ដែលរួមទាំងទឹកសម្រាប់ការស្រោចស្រពកសិកម្ម និងការប្រើប្រាស់ក្នុងទីក្រុង/ឧស្សាហកម្មថាមពលវារីអគ្គិសនីនៅតាមដៃទន្លេមេគង្គ និងការគ្រប់គ្រងហានិភ័យនៃទឹកជំនន់នៅក្នុងដែនដីសណ្តទន្លេមេគង្គផងដែរ។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ធ្វើឱ្យមានការផ្តោតនូវការយកចិត្តទុកដាក់កាន់តែខ្លាំងមកលើថាមពលវារីអគ្គិសនីនៅលើទន្លេមេនៃទន្លេមេគង្គ ថាមពលនៅថ្នាក់តំបន់ និងប៉ារ៉ាម៉ែត្រនៃថាមពល បង្កើនការ

យកចិត្តទុក ដាក់លើវដ្តនៃការកសាងផែនការសព្វថ្ងៃនេះ ក្នុងបំណងដោះស្រាយចំណោទនានាចំពោះមុខនៅក្នុងអាងទន្លេនេះ។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ផ្តល់នូវការបំពេញបន្ថែមលើការវាយតម្លៃសេណារីយ៉ូ តាមរយៈអនុសាសន៍នានាសម្រាប់ការបញ្ចៀស ការបន្ធូរបន្ថយ និងការបង្កើនវិធានការនានា។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រក៏ជួយដល់ប្រទេសជា សមាជិកក្នុងការពង្រីកជម្រើសនៃការកសាងផែនការរបស់ខ្លួនផងដែរ ដោយផ្តល់នូវការប៉ាន់ប្រមាណអំពីថាមពល តាមវិធីជំនួស។ ទាំងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេដោយផ្អែកលើគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ សុទ្ធតែផ្តល់នូវក្របខ័ណ្ឌគោលសម្រាប់វិភាគ ដែលនៅក្នុងនោះ មានរួមបញ្ចូលដំណើរការពិគ្រោះយោបល់ជាមុនរបស់គណៈកម្មការទន្លេមេគង្គផងដែរ អំពីគម្រោងនីមួយៗដាច់ដោយឡែកពីគ្នា។

- ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ផ្តល់នូវអនុសាសន៍ដែលដោះស្រាយផលប៉ះពាល់នៃសេណារីយ៉ូអភិវឌ្ឍ ដែលពិតជាកើតមានទៅអនាគតនៅក្នុងសេណារីយ៉ូពេលអនាគតច្បាស់លាស់របស់ផែនការអភិវឌ្ឍន៍អាងទន្លេ **(BDP's Definite Future Scenario)** : ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រផ្តល់អនុសាសន៍ដែលដោះស្រាយផលប៉ះពាល់ដែលអាចកើតពីសេណារីយ៉ូនៃការអភិវឌ្ឍជាក់ស្តែងទៅអនាគត ដែលរួមទាំងការគិតគូរអំពីប្រតិបត្តិការនៃទំនប់នៅលើដងទន្លេឡាំងឆាន-មេគង្គ នៅក្នុងប្រទេសចិន និងគម្រោងវារីអគ្គិសនីបន្ថែមចំនួន ២៨ នៅលើដៃទន្លេនានានៅក្នុងអាងទន្លេមេគង្គក្រោមផងដែរ។ នៅក្នុងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេដែលផ្អែកលើគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ យោងតាមសេណារីយ៉ូនៃអភិវឌ្ឍន៍អាងទន្លេ និងការវាយតម្លៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ប្រទេសជាសមាជិកបានឯកភាពក្នុងការចាត់ជាអាទិភាពនូវការបង្កើតវិធានការបន្ធូរបន្ថយសម្រាប់សេណារីយ៉ូពេលអនាគតច្បាស់លាស់ នៅក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។ យន្តការនេះនឹងបង្កើតជាផ្នែកមួយនៃការអនុវត្តនៅក្នុងដំណាក់កាលដើមដំបូងនៃយុទ្ធសាស្ត្រនេះ ក្រោយមានការអនុម័ត ដែលរំពឹងថានឹងធ្វើឡើងនៅក្នុងខែមករាឆ្នាំ ២០១០។

- ដំណើរការនៃការដាក់បញ្ចូលសមិទ្ធផលនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ទៅក្នុងផែនការអភិវឌ្ឍន៍អាងទន្លេត្រូវអនុវត្តជាប់ជាបន្ត: យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេដោយផ្អែកលើគោលការណ៍ការគ្រប់គ្រងធនធានទឹកចម្រុះ កំពុងស្ថិតក្រោមការធ្វើបច្ចុប្បន្នភាព នៅក្នុងការរៀបចំសម្រាប់សុំការអនុម័តឯកភាពពីក្រុមប្រឹក្សានៃគណៈកម្មការទន្លេមេគង្គ នៅក្នុងខែមករា ឆ្នាំ ២០១១។ តើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ អាចដាក់បញ្ចូលបែបណា ជាក់លាក់នៅក្នុងផែនការអភិវឌ្ឍន៍អាងទន្លេ គឺជាចំណុចសំខាន់មួយនៃការពិភាក្សា នៅក្នុងវេទិកានៃអ្នកពាក់ព័ន្ធនៅថ្នាក់តំបន់នៃផែនការអភិវឌ្ឍន៍អាងទន្លេ លើកទីបី ក្នុងពេលថ្មីៗនេះ និងកំពុងស្ថិត ក្រោមការពិនិត្យដោយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។ យុទ្ធសាស្ត្រនេះផ្អែកលើលទ្ធផលពីទាំងសេណារីយ៉ូនៃ ផែនការអភិវឌ្ឍន៍អាងទន្លេ និង ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដើម្បីបង្កើនការយល់ដឹងរួមគ្នាក្នុងចំណោមប្រទេស ជាសមាជិកអំពីឱកាស និងហានិភ័យនានាដែលទាក់ទងជាមួយការអភិវឌ្ឍធនធានទឹក ដែលរួមទាំង ការអភិវឌ្ឍថាមពល វារីអគ្គិសនីនៅក្នុងអាងទន្លេមេគង្គក្រោមផងដែរ។

ប្រការនេះនាំទៅរកកិច្ចព្រមព្រៀងលើការណែនាំយុទ្ធសាស្ត្រជាអាទិភាពមួយ ដែលប្រទេសជាសមាជិកនឹងយកទៅអនុវត្ត ដើម្បីបង្កើនឱកាស និងកាត់បន្ថយហានិភ័យ។ ដំណើរទាំងពីរផ្តល់ អនុសាសន៍ប្រហាក់ប្រហែលគ្នា អំពីតម្រូវការឱ្យមានការសិក្សាបន្ថែមទៀត ដើម្បីដោះស្រាយភាពមិនប្រាកដប្រជា ហើយប្រការទាំងនេះត្រូវបានដាក់បញ្ចូលជាចំណាត់ការអាទិភាពពីសំណាក់ប្រទេសជាសមាជិក និងគណៈកម្មការទន្លេមេគង្គ សម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ។ ចំពោះសំណើកសាងទំនប់លើដងទន្លេមេគង្គ ប្រការនេះរួមបញ្ចូលដំណើរការ នីតិវិធីនៃការជូនដំណឹងការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងរបស់ គណៈកម្មការទន្លេមេគង្គ និងដំណើរការវាយតម្លៃបរិស្ថានរបស់ជាតិ និងការចេញអាជ្ញាប័ណ្ណ។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ នេះនឹងត្រូវយកទៅប្រើប្រាស់សម្រាប់ជាមូលដ្ឋាន នៅក្នុងការពិភាក្សាលំអិតអំពីគម្រោងថាមពលវារីអគ្គិសនីនៅក្នុងអំឡុងពេលនៃដំណើរការពិនិត្យឡើងវិញទាំងនោះ ចំណែកផែនការអភិវឌ្ឍន៍អាងទន្លេផ្តល់នូវទិដ្ឋ ភាពធំទូលាយជាងមួយនៃផលប៉ះពាល់សរុប បណ្តាលពីការអភិវឌ្ឍថាមពលវារីអគ្គិសនី និងការអភិវឌ្ឍធនធានទឹកតាមបែបផ្សេង។

## របាយការណ៍ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និង នីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង

*តើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រទាក់ទងបែបណា ជាមួយនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង?*

- ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ គោរពតាមដំណើរការ នីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងដើម្បីធានាឱ្យមានកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ : នៅថ្នាក់តំបន់ ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ បានអនុម័តពិធីសារមួយនៅក្រោមកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥ ដែលតម្រូវឱ្យ ប្រទេសទាំងនេះដាក់ជូនសំណើគម្រោងនៅលើដងទន្លេមេគង្គ ទៅប្រទេសផ្សេងទៀតដែលជាសមាជិកមុននឹង ធ្វើការសម្រេចអភិវឌ្ឍន៍។ ដំណើរការនេះទាមទារឱ្យមានការពិគ្រោះយោបល់ទូលំទូលាយជាមុន ដែលមានគោលដៅឈាន ដល់កិច្ចព្រមព្រៀងលើថាតើគួរសម្រេចអនុវត្តគម្រោងដែរឬទេ ហើយប្រសិនបើត្រូវអនុវត្ត តើធ្វើនៅក្រោមលក្ខខណ្ឌបែបណា។ ដំណើរការទាំងមូលនៃនីតិវិធីនៃការជូនដំណឹងការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងបានធ្វើឡើងជាលើកដំបូងដោយ រដ្ឋាភិបាលនៃប្រទេសឡាវសម្រាប់សំណើគម្រោងថាមពលវារីអគ្គិសនី សាយ៉ាប៊ូរី នៅ ក្នុងខែ កញ្ញា ឆ្នាំ ២០១០។

- ការ វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ មានការពាក់ព័ន្ធជិតស្និទ្ធជាមួយនីតិវិធីរបស់ គណៈកម្មការទន្លេមេគង្គ ស្តីពីការជូនដំណឹង ដំណើរការពិគ្រោះយោបល់ និងការព្រមព្រៀងជាមុន (PNPCA) : នីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងផ្តល់នូវក្របខ័ណ្ឌមសម្រាប់ការវិភាគហានិភ័យ និងឱកាសសម្រាប់អភិវឌ្ឍន៍នៅលើដងទន្លេមេគង្គ ដែលក្នុងនោះគម្រោងនីមួយៗ ដូចជា គម្រោងសាយ៉ាប៊ូរី  នឹងត្រូវស្ថិតក្រោមការវាយតម្លៃ។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ពិនិត្យមើលផលប៉ះពាល់ សរុប និងចំណោទអំពីរបាយផលចំណេញ និងផលប៉ះពាល់។

- ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ មានការពាក់ព័ន្ធជិតស្និទ្ធជាមួយដំណើរការ នីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងក្នុងនាមជាយោបល់បច្ចេកទេស ប៉ុន្តែវាក៏ជាដំណើរការមួយផងដែរ : គណៈកម្មការទន្លេមេគង្គបាន និងកំពុងធ្វើការដោយគិតគូរជាមុន ដើម្បីជួយប្រទេសជាសមាជិកក្នុងការរៀបចំធ្វើការសម្រេចលើសំណើគម្រោងថាមពលនៅលើទន្លេមេនៃទន្លេមេគង្គ។ ការងារជាច្រើនខាងការស្រាវជ្រាវរបស់ គណៈកម្មការទន្លេមេគង្គ នៅក្នុងរយៈពេលជាច្រើន ឆ្នាំកន្លងមកនេះ លើកិច្ចការបរិស្ថាន និងជលផល ត្រូវបានយកមកប្រើប្រាស់នៅក្នុង ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ហើយនៅក្នុងដំណើរការនេះ របកគំហើញទាំងនោះត្រូវបានប្រមូលចងក្រង និងសំយោគ។ ដំណើរការការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រផ្ទាល់ មានរួមបញ្ចូលនូវការពិគ្រោះយោបល់នៅ ថ្នាក់ជាតិ និងថ្នាក់តំបន់ ដែលភាគីទាំងអស់ក្នុងពេលសព្វថ្ងៃនេះ មានការយល់ដឹងច្រើនជាងមុន អំពីកិច្ចការនានា និងទំនុកចិត្តលើអភិក្រមនៃ អ្នកពាក់ព័ន្ធច្រើន។ ប្រការនេះនឹងអាចឱ្យនីតិវិធីនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងចាប់ផ្តើម ឈានទៅកម្រិតដែលកាន់តែមានការយល់ដឹង និងសហប្រតិបត្តិការកម្រិតខ្ពស់ជាងមុនផងដែរ។ ស្របជាមួយកិច្ចព្រមព្រៀង ទន្លេមេគង្គឆ្នាំ ១៩៩៥ ការពិគ្រោះយោបល់ជាមុនយ៉ាងស្វាហាប់ ដែលមានគោលដៅឈានទៅដល់កិច្ចព្រមព្រៀងមួយ ពីគណៈកម្មាធិការរួមនៃ គណៈកម្មការទន្លេមេគង្គ គឺជាប្រការចាំបាច់។ នៅទីបំផុត ប្រការនេះនឹងក្លាយជាដំណើរការចរចាមួយ ដែលផ្អែកលើមូលដ្ឋាននៃចំណេះដឹង ដែលគណៈកម្មការទន្លេមេគង្គ និងស្ថាប័នដទៃទៀត ប្រមូលចងក្រង និងដែលមាន សង្ខេបនៅក្នុងរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ នេះ។